# កម្មវិធីដាំដើមហូបផ្លែរបស់សាលាក្រុងឡុងប៊ិច
# ទម្រង់បែបបទ ស្តីពីការយល់ព្រមនិងការលះបង់សិទ្ធិជាប់កាតព្វកិច្ច

## សេចក្តីថ្លែងរបស់ម្ចាស់អចលនទ្រព្យ ៖

1. ខ្ញុំដូចមានចុះហត្ថលេខាខាងក្រោមនេះ («ម្ចាស់អចលនទ្រព្យ») យល់ព្រមចូលរួម ដោយស្ម័គ្រចិត្ត ក្នុង **កម្មវិធីដាំដើមហូបផ្លែ របស់សាលាក្រុងឡុងប៊ិច** («កម្មវិធី») ។ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំគឺជាម្ចាស់ អចលនទ្រព្យ មាននៅក្នុងបញ្ជី ដូចមានរៀបរាប់ ខាងក្រោមនេះ («អចលនទ្រព្យ») ។
2. ខ្ញុំយល់ដឹងថា ជាផ្នែកនៃការចូលរួម របស់ខ្ញុំ នៅក្នុងកម្មវិធី, ខ្ញុំអាចទទួលបាន ដើមហូបផ្លែ មួយ ដើម សម្រាប់ដាំ នៅក្នុងអចនទ្រព្យ របស់ខ្ញុំ ស្របទៅតាមមូលនិធិកម្មវិធីដែលមាន ។
3. ដោយចុះហត្ថលេខានៅខាងក្រោមនេះ, ខ្ញុំផ្តល់លទ្ធភាពចេញចូល និង ការយល់ព្រមសម្រាប់ការ យកដើមរុក្ខជាតិ ទៅដាំនៅក្នុងអចលនទ្រព្យ របស់ខ្ញុំ ដោយសាលាក្រុងឡុងប៊ិច («សាលាក្រុង») ព្រមទាំង តំណាង, ភ្នាក់ងារ, អ្នកម៉ៅការបន្ត និងអ្នកប្រឹក្សា គ្រប់ជាន់ថ្នាក់របស់សាលាក្រុង។ ការដាំដើមរុក្ខជាតិរបស់កម្មវិធីអាចធ្វើទៅបាន នៅពេលដែលសមស្រប សម្រាប់សាលាក្រុង ។
4. ខ្ញុំទទួលស្គាល់ថាសាលាក្រុងអាចធ្វើការផ្លាស់ប្តូរដែលមានការណែនាំ ចំពោះអចលនទ្រព្យក្រោយ ពេលមានការចុះវាយតម្លៃទីកន្លែង; ថាការណែនាំ ដែលបានលើកឡើងនោះ ត្រូវបំពេញក្រោម បន្ទុកចំណាយផ្ទាល់ របស់ខ្ញុំ; និងថា ការខកខានមិនធ្វើការផ្លាស់ប្តូរ ដែលមានការណែនាំ ប្រសិនបើមាន អាចធ្វើឱ្យអចលនទ្រព្យ របស់ខ្ញុំ អស់គុណវឌ្ឍន៍ ក្នុងការចូលរួមកម្មវិធី ហើយធ្វើ ឱ្យខ្ញុំ មិនទទួលបាន ដើមរុក្ខជាតិនោះទេ ។
5. ខ្ញុំទទួលដឹងថា សាលាក្រុង ត្រូវធ្វើការសម្រេចចុងក្រោយ លើការកំណត់ទីតាំងដាំដើមរុក្ខជាតិ របស់កម្មវិធី, និងថា ការចង់បាន របស់ម្ចាស់ ដែលមានបញ្ជាក់ប្រាប់ណាមួយ គឺមិនមានចង ជា កាតព្វកិច្ចនោះទេ ហើយនឹងបម្រើជាការតម្រង់ទិស សម្រាប់ដាក់ដាំដើមរុក្ខជាតិតែប៉ុណ្ណោះ ។
6. សាលាក្រុងនឹងទទួលខុសត្រូវ តែលើការជីរណ្តៅ សម្រាប់ដាំប៉ុណ្ណោះ ។ ម្ចាស់អចលនទ្រព្យ នឹង ទទួលខុសត្រូវលើការផ្លាស់ប្តូរណាមួយ និងផ្សេងៗ ទៀត ទាំងអស់ ដែលចាំបាច់ ចំពោះអច លនទ្រព្យ របស់ពួកគេ រួមទាំង តែមិនកម្រិតត្រឹម ការកែតម្រូវដីសួន, ការកែតម្រូវប្រព័ន្ធស្រោច ស្រព ដែលមានស្រាប់, ឬ ការកែតម្រូវចាំបាច់ផ្សេងៗទៀតស្របតាមការតម្រូវ ដោយសាលាក្រុង ក្រោមការសម្រេចផ្ទាល់របស់សាលាក្រុង ។
7. ខ្ញុំទទួលស្គាល់ថា កាលបរិច្ឆេទនិងពេលវេលា ក្នុងការដាំដើមរុក្ខជាតិ អាចកែប្រែ, អចលនទ្រព្យ របស់ខ្ញុំ អាចត្រូវមិនជ្រើសយក ឬ ដកចេញ ពីកម្មវិធី, ឬ កម្មវិធី អាចត្រូវលុបចោល ដោយមាន ឬគ្មាន សេចក្តីជូនដំណឹង តាមការសម្រេចផ្ទាល់របស់សាលាក្រុង ។
8. ខ្ញុំយល់ដឹងថា កម្មវិធីទទួលបានមូលនិធិ ពីជំនួយឥតសំណងផ្នែករុក្ខជាតិ ក្នុងទីក្រុង CalFire (Urban Forestry grant), ហើយសាលាក្រុងរក្សាសិទ្ធិ ក្នុងការចេញ និងចូល ទៅក្នុងអចលនទ្រព្យ បានគ្រប់ពេលដោយមាន ឬ គ្មានសេចក្តីជូនដំណឹង ដើម្បីពិនិត្យមើល ការងារដែលបានបំពេញ រួច និងធ្វើការពិនិត្យមើល ជាប្រចាំ លើទីតាំង, ការលូតលាស់, និង សុខភាព របស់ រុក្ខជាតិ របស់ កម្មវិធី ក្នុងកំឡុងពេល ដែលអនុញ្ញាតឱ្យ (30 ខែកញ្ញា ឆ្នាំ 2018 ដល់ 30 ខែមិថុនា ឆ្នាំ 2021) ។
9. ម្ចាស់ ម្នាក់ៗ នឹងទទួលបាន «មគ្គុទេសក៍ ស្តីពីការមើលថែ» ដើមហូបផ្លែ មួយច្បាប់ ។ ខ្ញុំទទួល ស្គាល់ថានៅពេលមានការផ្លាស់ប្តូរកម្មសិទ្ធិ ឬ ការកាន់កាប់, «មគ្គុទេសក៍ ស្តីពីការមើលថែ» ត្រូវ តែស្ថិតនៅ ក្នុងអចលនទ្រព្យដដែល ហើយខ្ញុំត្រូវជូនព័ត៌មាន ដល់ម្ចាស់ ឬ អ្នកជួលថ្មី ។
10. ខ្ញុំ យល់ព្រម និង ផ្តល់ការអនុញ្ញាត ដល់សាលាក្រុង ក្នុងការថតយករូបភាព អចលនទ្រព្យ របស់ ខ្ញុំ និងភាពស្រដៀង ជារូបថត, វីដេអូ, រូបភាព មានចលនា, កំណត់ត្រា, ឬ ឯកសារផ្សព្វផ្សាយ ផ្សេងៗ ទៀត (ហៅជារួមថា «រូបភាព») ។ ខ្ញុំទទួលស្គាល់ថាសាលាក្រុង នឹងកាន់កាប់រូបភាពទាំង នោះ ហើយផ្តល់ការអនុញ្ញាតបន្ថែមទៀត ដល់សាលាក្រុង ចំពោះសិទ្ធិថតចម្លង, ដាក់បង្ហាញ, ផ្សព្វផ្សាយ, ចែកចាយ, ប្រើប្រាស់, កែខៃ, បោះពុម្ព និង បោះពុម្ពឡើងវិញ លើរូបភាពទាំងនោះ ក្នុងលក្ខណៈណាក៏បានដែរ ។ លើសពីនេះទៅទៀត ខ្ញុំលះបង់សិទ្ធិ ក្នុងការពិនិត្យមើល ឬ ផ្តល់ការ ឯកភាព លើការប្រើប្រាស់រូបភាព ដោយសាលាក្រុង មុនពេលមានការប្រើប្រាស់ ។ ជារៀងរហូត ទៅ ខ្ញុំនឹងបើកហើយដាក់មិនឱ្យ សាលាក្រុង រងមហន្តរាយ ពីបន្ទុកណាមួយ និងទាំងអស់ ដែល កើតចេញពីការប្រើប្រាស់រូបភាព ក្នុងលក្ខណៈណាមួយ ឬ ឯកសារផ្សព្វផ្សាយអ្វីមួយ ហើយលះបង់ សិទ្ធិ ដាក់រាល់បណ្តឹងទាមទារ និងបុព្វហេតុចាត់វិធានការ ទាំងអស់ ពាក់ព័ន្ធនឹង ការប្រើប្រាស់

រូបភាព រួមទាំង តែមិនកម្រិតត្រឹមបណ្ដឹង ចំពោះការចូលឈ្លានពានលើសិទ្ធិឯកជន ឬ សាធារណៈ ។

11. ជាការដោះដូរ នឹងការទទួលបានដើមរុក្ខជាតិមួយដើម សម្រាប់អចលនទ្រព្យខ្ញុំ, ខ្ញុំបានយល់ព្រមទទួលរាល់ហានិភ័យទាំងអស់ ដែលពាក់ព័ន្ធ ហើយលះបង់សិទ្ធិដាក់រាល់បណ្ដឹងទាមទារ ឬ បុព្វហេតុចាត់វិធានការ ទាំងអស់ ដែលកើតចេញពី ការចូលរួមក្នុងកម្មវិធី របស់ខ្ញុំ រួមទាំង តែមិនកម្រិតត្រឹម ផលជះ ពីដើមរុក្ខជាតិ របស់កម្មវិធី ទៅលើអចលនទ្រព្យ ក្នុងកំឡុងពេលដាំ និងក្រោយពេលដាំរួច ។

12. ជាងនេះទៅទៀត ខ្ញុំយល់ព្រមបើក, ដោះបន្ទុក, ធានាសង និង ដាក់មិនឱ្យ សាលាក្រុងឡុងប៊ិច, គណៈកម្មាធិការ, គណៈកម្មការ, ព្រមទាំង មន្ត្រី, និយោជិត និង ភ្នាក់ងារ របស់សាលាក្រុង (ហៅជារួមថា «សាលាក្រុង») រងមហន្តរាយ ពីរាល់បន្ទុក, ការខាតបង់, ការខូចខាត, ថ្លៃដើម, ចំណាយ និងបណ្ដឹងទាមទារ ក្នុងលក្ខណៈណាមួយ ដែលសាលាក្រុង អាចទទួលបាន, ទទួលរង, ឬ តតាំង ដោយសារមូលហេតុ ឬ រឿង ណាមួយពាក់ព័ន្ធនឹង ការចូលរួមក្នុងកម្មវិធីរបស់ខ្ញុំ ។

______________________________
វាយឈ្មោះម្ចាស់អចលនទ្រព្យ

______________________________
អាសយដ្ឋានអចលនទ្រព្យ

______________________________
ហត្ថលេខា របស់ម្ចាស់អចលនទ្រព្យ

______________________________
កាលបរិច្ឆេទថ្ងៃចុះហត្ថលេខា